ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ថវិកាសង្ខេប ឆ្នាំ ២០២៤

# BUDGET IN BRIEF

## Fiscal Year 2024

**នាយកដ្ឋានថវិកានីយកម្ម**

**អគ្គនាយកដ្ឋានថវិកា**



# មាតិកា

ទំព័រ


**ជំពូក ១. សេចក្តីផ្តើម** ២

១.១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២៤ ២

១.២. បញ្ហាប្រឈម និង ហានិភ័យ ៤

១.៣. គោលការណ៍សំខាន់ៗនៃការរៀបចំថវិកាឆ្នាំ ២០២៤ ៤

**ជំពូក ២. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៤** ៦

២.១. សូចនាករសេដ្ឋកិច្ច ៦

២.២. កំណើនតាមវិស័យសំខាន់ៗ ៨

**ជំពូក ៣. ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៤** ១០

៣.១. ស្ថានភាពចំណូលថវិការដ្ឋ ១៣

៣.២. ស្ថានភាពចំណាយថវិការដ្ឋ ១៤

៣.៣. ថវិកាថ្នាក់ជាតិ ១៥

៣.៤. ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ២៤

៣.៥. ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០២៤ ២៧

៣.៦. ស្ថានភាពបំណុល ៣០

**ជំពូក ៤. សេចក្តីសន្និដ្ឋាន** ៣១

**ជំពូក ៥. តារាងឧបសម្ព័ន្ធ** ៣៣

៥.១. ថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័ន តាមកម្មវិធី អនុកម្មវិធី ៣៣

៥.២. ចំណាយថវិកាសរុបរបស់ក្រសួង ស្ថាប័ន ៦២

# ជំពូក ១. សេចក្តីផ្តើម

## ១.១. បរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០២៤

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ ត្រូវបានរៀបចំឡើង នៅក្នុងបរិការណ៍ដែលរាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បន្តទទួលបាននូវទំនុកចិត្តដ៏ច្រើនលើសលប់ចេញពីឆន្ទៈរបស់ប្រជាជនកម្ពុជានៅទូទាំងប្រទេស ឱ្យបំពេញបេសកកម្មដឹកនាំប្រទេសជាតិសម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា តពីរាជរដ្ឋាភិបាលនីតិកាលទី ៦។ ឈរលើមូលដ្ឋាននេះ, ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៤ មានគោលដៅគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ជាពិសេសការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និង វិធានការកែទម្រង់ជាក់ស្តែងនានា ដែលត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ចាប់ពីដើមនីតិកាលទី ៧ នៃរដ្ឋសភា ឱ្យសម្រេចបាននូវលទ្ធផលផ្លែផ្កាជាអតិបរមា ដើម្បីឆ្លើយតបទៅនឹងសំណូមពរ សេចក្តីត្រូវការ និងការរំពឹងទុករបស់ប្រជាជនកម្ពុជាដែលជាម្ចាស់ឆ្នោត នៅក្នុងដំណាក់កាលថ្មីនៃការអភិវឌ្ឍ។ ទោះជាយ៉ាងនេះក្តី, នៅក្នុងបរិការណ៍ដែលកម្ពុជាកំពុងទទួលផលពីសុខសន្តិភាព និងស្ថិរភាពនយោបាយក្នុងប្រទេស ហើយសេដ្ឋកិច្ចក៏កំពុងងើបឡើងវិញ និងត្រឡប់ទៅរកភាពប្រក្រតីក្រោយវិបត្តិនៃជំងឺកូវីដ-១៩, កម្ពុជា ក៏នៅមានបញ្ហាប្រឈមជារចនាសម្ព័ន្ធខាងក្នុងមួយចំនួន ដែលធ្វើឱ្យដំណើរការពិពិធកម្មសេដ្ឋកិច្ចមិនទាន់អាចសម្រេចបានក្នុងល្បឿនខ្ពស់តាមការរំពឹងទុកហើយភាពប្រកួតប្រជែងក៏នៅមានកម្រិត។ ម៉្យាងទៀត, កម្ពុជា ក៏ដូចជាបណ្តាប្រទេសដទៃទៀតលើសកលលោកកំពុងត្រូវបានបន្តហ៊ុមព័ទ្ធដោយហានិភ័យ និង ភាពមិនប្រាកដប្រជាខ្ពស់ពីកត្តាខាងក្រៅធំៗ មានជាអាទិ៍÷ ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ; កំណើនទាបនៃសេដ្ឋកិច្ចសកល ដែលបណ្តាលមកពីសង្គ្រាមពាណិជ្ជកម្ម; ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ ក្នុងការឆ្លើយតបទៅនឹងសម្ពាធអតិផរណា; ការអូសបន្លាយនៃសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន; បញ្ហាសង្គ្រាមអ៊ីស្រាអែល-ហាម៉ាសក៏ដូចជាបញ្ហាកំណើនទាបនៃសេដ្ឋកិច្ចចិន។ លើសពីនេះទៀត, ការប្រែប្រួលអាកាសធាតុ, ដែលជាបញ្ហាប្រឈមរបស់មនុស្សជាតិ និងប្រទេសនីមួយៗ, ក៏កំពុងតែបន្តផលប៉ះពាល់អវិជ្ជមានកាន់តែធ្ងន់ធ្ងរ។ ជារួម, ហានិភ័យ និងបញ្ហាប្រឈមទាំងនេះ បាននិងកំពុងបង្កផលប៉ះពាល់លើពាណិជ្ជកម្មអន្តរជាតិ និងលំហូរនៃការវិនិយោគមកកម្ពុជា ដែលអាចយាយីដល់កិច្ចខិតខំប្រឹងប្រែង

របស់កម្ពុជាក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាអាចប៉ះទង្គិចដល់គន្លងនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។

ក្នុងបរិការណ៍នេះ, ថវិកាឆ្នាំ ២០២៤ ត្រូវបានគិតគូរ និង រៀបចំឡើង ដើម្បីទ្រទ្រង់ដល់ការថែរក្សានូវសមិទ្ធផលនានា ដែលសម្រេចបានមកដោយលំបាក ក៏ដូចជាការអនុវត្តអាទិភាពគោលនយោបាយសំខាន់ៗ និង វិធានការកែទម្រង់ជាក់ស្តែងនានា ដើម្បីឆ្លើយតបទៅនឹងបរិការណ៍ថ្មីរបស់កម្ពុជា, ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងប្រទេស និងក្នុងក្របខ័ណ្ឌតំបន់ និង ពិភពលោក, ជាពិសេស ដើម្បីសម្រេចឱ្យបានជាអតិបរមានូវ គោលដៅជាយុទ្ធសាស្ត្រ ទាំង ៥ ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ- ដំណាក់កាលទី ១ ដើម្បីកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០, ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា។ ទន្ទឹមនេះដែរ, ថវិកាឆ្នាំ ២០២៤ ក៏បានផ្តោតការយកចិត្តទុកដាក់លើ អាទិភាពគន្លឹះចំនួន ៥ នៃយុទ្ធសាស្ត្របញ្ចកោណ- ដំណាក់កាលទី ១, ដោយក្នុងនោះ មនុស្ស ត្រូវបានបន្តកំណត់យកជាអាទិភាពគន្លឹះទី ១, ហើយ ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យា ជាអាទិភាពគន្លឹះបន្តបន្ទាប់តាមលំដាប់ ដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និង ទិសដៅនៃការអភិវឌ្ឍកម្ពុជាក្នុងដំណាក់កាលថ្មីខាងមុខ ដែលរួមមាន÷ (១)- ការអភិវឌ្ឍមូលធនមនុស្ស, (២)- ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង, (៣)- ការអភិវឌ្ឍវិស័យឯកជន និងការងារ, (៤)- ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាប័ន្ន, និង (៥)- ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ បន្ថែមលើនេះ, ថវិកាឆ្នាំ ២០២៤ ក៏ត្រូវបានរៀបចំឡើងក្នុងគោលដៅគាំទ្រដល់ការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពចំនួន ៦ របស់រាជរដ្ឋាភិបាល ចាប់ពីដើមនីតិកាលទី ៧ នេះ ព្រមទាំងវិធានការគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមជាអាទិភាពចំនួន ៥ ទៀត ដែលត្រូវបានដាក់ចេញដោយ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងកិច្ចប្រជុំពេញអង្គលើកដំបូងនៃគណៈរដ្ឋមន្ត្រី នីតិកាលទី ៧ នៃរដ្ឋសភា កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០២៣ កន្លងទៅ។

## ១.២. បញ្ហាប្រឈម និង ហានិភ័យ

សម្រាប់ឆ្នាំ ២០២៤ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថា នឹងសម្រេចបានកំណើនក្នុងរង្វង់ **៦,៦%** ក្នុងបរិបទនៃការកើនឡើងនូវបញ្ហាប្រឈម និងហានិភ័យទាំងក្នុង និងក្រៅប្រទេស ដែលបាន និងកំពុងបង្កការគំរាមមកលើចីរភាព និងនិរន្តរភាពនៃការអភិវឌ្ឍកម្ពុជា ដូចជា÷

(ទី១)- ការកើនឡើងនូវភាពតានតឹងភូមិសាស្ត្រនយោបាយតំបន់ និងសកល,

(ទី២)-ការថមថយសេដ្ឋកិច្ចសកល ជាពិសេសបណ្តាប្រទេសដែលជាដៃគូពាណិជ្ជកម្មកម្ពុជា,

(ទី៣)- ការបន្តរឹតបន្តឹងយូរជាងការរំពឹងទុកនៃគោលនយោបាយរូបិយវត្ថុ ជាពិសេស សហរដ្ឋអាមេរិក និងការបន្តកើនឡើងថ្លៃរូបិយប័ណ្ណដុល្លារអាមេរិក ដែលអាចប៉ះពាល់ដល់លំហូរទុនវិនិយោគ និងពាណិជ្ជកម្ម,

(ទី៤)- ការបន្តឡើងថ្លៃ ឬកម្រិតខ្ពស់នៃថ្លៃថាមពល និងទំនិញជារួមលើទីផ្សារអន្តរជាតិ,

(ទី៥)- ការបែកខ្ញែកភូមិសាស្ត្រសេដ្ឋកិច្ចកំពុងកាត់បន្ថយនូវការចូលរួមក្នុងចរន្តសកលភាវូបនីយកម្ម ស្របជាមួយនឹងការកើនឡើងនៃនិន្នាការពហុប៉ូល និងការបែងចែកប្លុកសេដ្ឋកិច្ច និងពាណិជ្ជកម្ម,

(ទី៦)-ការកើនឡើងនូវផលប៉ះពាល់ជាអវិជ្ជមានកាន់តែធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ។

ជាមួយគ្នានេះ, កម្ពុជានៅបន្តប្រឈមនឹងបញ្ហាជារចនាសម្ព័ន្ធខាងក្នុងមួយចំនួន ពិសេស ភាពប្រកួតប្រជែងនៅមានកម្រិត និងល្បឿនយឺតនៃការធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងការបន្តពឹងផ្អែកខ្លាំងលើតម្រូវការខាងក្រៅ។

## ១.៣. គោលការណ៍សំខាន់ៗនៃការរៀបចំច្បាប់ថវិកាឆ្នាំ ២០២៤

ថវិកាឆ្នាំ ២០២៤ ត្រូវបានរៀបចំឡើងដោយផ្អែកលើ **គោលការណ៍គ្រឹះជាយុទ្ធសាស្ត្រ** សំខាន់ៗ ដូចខាងក្រោម÷

ទី ១)- **គោរពឱ្យបាននូវក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលត្រូវបានកំណត់ ជាពិសេសគាំទ្រដល់ការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវវិធានការគោលនយោបាយគន្លឹះដែលត្រូវបានដាក់ចេញ** ដើម្បីសម្រេចគោលដៅនៃកំណើនសេដ្ឋកិច្ច ក្នុងរង្វង់ ៦,៦% ដែលជាមូលដ្ឋានមិនអាចខ្វះបាន ដើម្បីបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន, ជាពិសេស សម្រាប់យុវជន, និងផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ផង ក៏ដូចជាដើម្បីបង្កើនចំណូលថវិកាជាតិផងដែរ។

ទី ២)- **រក្សាតុល្យភាព និងចីរភាពថវិកា** ពោលគឺ រក្សាតុល្យភាពនៃតម្រូវការចំណាយដោយផ្អែកលើលទ្ធភាពចំណូលថវិកា ដែលមានប្រភពពីការប្រមូលចំណូលក្នុងប្រទេស ដោយចៀសវាងការដកប្រាក់សន្សំរបស់រាជរដ្ឋាភិបាលយកមកប្រើ, ទន្ទឹមនឹងការពង្រឹងការគ្រប់គ្រងការខ្ចីក្នុង និងក្រៅប្រទេស ដោយប្រកាន់ខ្ជាប់នូវគោលការណ៍វិន័យគន្លឹះទាំង ៥ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ។

ទី ៣)- **ធានាចីរភាព និងសមិទ្ធកម្មនៃចំណូល÷** ដើម្បីសម្រេចបាននូវគោលដៅនៃការប្រមូលចំណូលតាមការកំណត់ ក៏ដូចជាដើម្បីឆ្លើយតបនឹងតម្រូវការចំណាយថវិកាជាតិនៅក្នុងឆ្នាំ ២០២៤ ក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលដែលទទួលបន្ទុកកៀរគរចំណូលមិនមែនសារពើពន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលទទួលបន្ទុកកៀរគរចំណូលសារពើពន្ធចាំបាច់ត្រូវបន្តរក្សាចលនការនៃកិច្ចប្រឹងប្រែងក្នុងការកៀរគរចំណូលថវិកាឱ្យអស់សក្តានុពល, ទន្ទឹមនឹងការបន្តរក្សានូវភាពប្រយ័ត្នប្រយែង ដោយចៀសវាងនូវការបង្កផលប៉ះពាល់ជាអវិជ្ជមានដល់ការរស់នៅរបស់ប្រជាជន ការធ្វើធុរកិច្ច ព្រមជាមួយនឹងការបន្តខិតខំពង្រឹងអភិបាលកិច្ច និងយុត្តិធម៌ក្នុងការផ្តល់សេវា និងការប្រមូលពន្ធដារ។

ទី ៤)- **តម្កល់ "មនុស្ស" ជាអាទិភាពទី ១** ដោយផ្តោតលើ÷ (១)- ការបន្តដំឡើងបៀវត្សជូនមន្ត្រីរាជការក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅ និងបង្កើនផលិតភាពការងារ; (២)- ការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន ដោយដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ជាពិសេសផ្តល់ការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ; (៣)- ការលើកកម្ពស់គុណភាពអប់រំ និងគុណភាពសេវាសុខាភិបាល តាមរយៈការដាក់ឱ្យអនុវត្តនូវវិធានការគន្លឹះជាក់ស្តែងនានា; (៤)- ការដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈជាអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ជាពិសេសការកាត់បន្ថយគម្លាតប្រាក់សោធនរវាងអ្នកចូលនិវត្តចាស់ និង ថ្មី; និង (៥)- ការពង្រឹង និងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយគាំពារសង្គម សំដៅកសាងភាពធន់រឹងមាំប្រកបដោយចីរភាពនៃវិស័យមូលធនមនុស្ស និងសង្គម។

ទី ៥)- **ធ្វើវិចារណកម្មលំដាប់អាទិភាព** តាមរយៈ÷ (១)- ការបន្តប្រកាន់ខ្ជាប់នូវការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកា ដោយផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យអាទិភាព ជាពិសេសតម្រង់លើកម្មវិធី/សកម្មភាពចាំបាច់ជាអាទិភាពរបស់ក្រសួង-ស្ថាប័ន ស្របតាមកម្មវិធីគោលនយោបាយអាទិភាពដែលបានដាក់ចេញដើម្បីអនុវត្តភ្លាមពីដើមនីតិកាល និងវិធានការគន្លឹះរបស់រាជរដ្ឋាភិបាល ដែលត្រូវដោះស្រាយនៅក្នុងនីតិកាលទី ៧ នៃរដ្ឋសភា និង (២)- ការជំរុញអនុវត្ត

វិធានការបច្ចេកទេសលម្អិត ចំនួន ៤ រួមមាន÷ (ក)-តម្រង់ការបែងចែកថវិកាឱ្យបានត្រឹមត្រូវ និង ចំគោលដៅ ដោយមិនផ្តល់ថវិកាសម្រាប់មុខចំណាយមិនចាំបាច់ និងចំណាយលែងចាំបាច់;

ទី ៦)- **កែលម្អការរៀបចំកម្មវិធី/ សកម្មភាព** ដោយបន្តគិតគូរឱ្យកាន់តែម៉ត់ចត់លើភាពសមស្របនៃថ្លៃបរិមាណ និងគុណភាព ក្នុងការអនុវត្តកម្មវិធីសកម្មភាព ក្នុងគោលដៅបន្តលើកកម្ពស់បន្ថែមនូវប្រសិទ្ធភាពនៃ ការវិភាជថវិកា ក៏ដូចជាគុណភាពនៃសូចនាករគន្លឹះ។

ទី ៧)- **ផ្ទេរថវិកាឱ្យដល់អង្គភាពអនុវត្ត** ពោលគឺជំរុញ និងបង្កើនការផ្ទេរថវិកាឱ្យទៅដល់អង្គភាពថវិកា ជាពិសេសតាមសាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព ទន្ទឹមនឹងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងការទទួលខុសត្រូវនៅនឹងកន្លែង។

ទី ៨)- **ផ្សារភ្ជាប់រវាងការប្រមូលចំណូល និងការវិភាជថវិកា** ដោយផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងលទ្ធផលនៃការអនុវត្តចំណូល ជាពិសេសផ្តល់អាទិភាពចំណាយមិនមែនបុគ្គលិកដល់ក្រសួង-ស្ថាប័ន ដែលកៀរគរចំណូលដោយការខិតខំធ្វើសកម្មភាពរបស់ខ្លួនផ្ទាល់។ ទន្ទឹមនេះក៏លើកទឹកចិត្តឱ្យក្រសួង-ស្ថាប័នដែលទទួលបានរង្វាន់ពីការផ្តល់សេវាសាធារណៈ ប្រើប្រាស់ប្រាក់រង្វាន់ប្រកបដោយតម្លាភាព ដោយបែងចែកប្រាក់រង្វាន់ក្នុងទំហំសមស្រប សម្រាប់ការអភិវឌ្ឍសមត្ថភាពស្ថាប័ន។

## ជំពូក ២. ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០២៤

### ២.១. សូចនាករសេដ្ឋកិច្ច

តាមការព្យាករណ៍ សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២៤ ត្រូវបានព្យាករថានឹងងើបឡើងវិញហើយរំពឹងថានឹងសម្រេចបានកំណើនក្នុងរង្វង់ **៦,៦%** ដែលធ្វើឱ្យ ផសស ថ្លៃបច្ចុប្បន្ន ស្ថិតក្នុងរង្វង់ **១៤២ ៩៥៧** ប៊ីលានរៀល, សមមូលនឹងប្រមាណ **៣៥ ១៦៨** លានដុល្លារអាម៉េរិក, ស្របពេលដែល ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ **២ ០៧១** ដុល្លារអាម៉េរិក បើប្រៀបធៀបនឹង **១ ៩១៧** ដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២៣។ ចំណែក**អត្រាប្តូរប្រាក់រៀល**គឺនៅតែបន្តស្ថិតនៅក្នុងរង្វង់ **៤ ០៦៥** រៀល ក្នុងមួយដុល្លារអាម៉េរិក ក្នុងឆ្នាំ ២០២៤។ **ឱនភាពគណនីចរន្ត** (រួមបញ្ចូលបង្វែរ) ត្រូវបានព្យាករថានឹងរួមតូចបន្តិចមកត្រឹម **៩,៦%** នៃ ផសស ដោយសារការរំពឹងទុកលើការបន្តកើនឡើងនូវការនាំចេញ និងចំណូលពីវិស័យទេសចរណ៍។ **ទុនបម្រុងអន្តរជាតិសរុប** ត្រូវបានរំពឹងថានឹងកើនឡើងដល់ **២១ ២៨៥** លានដុល្លារអាម៉េរិក និងធានាការនាំចូលបាន **៦,៦** ខែ។

| សូចនាករសេដ្ឋកិច្ច | ២០២២ | ២០២៣ | ២០២៤ |
|---|---|---|---|
| | | ប៉ាន់ស្មាន | ព្យាករណ៍ |
| ផ.ស.ស. ថ្លៃបច្ចុប្បន្ន (ប៊ីលានរៀល) | 12 989 | 130 805 | 142 957 |
| កំណើននៃ ផ.ស.ស. តាមថ្លៃថេរ (%) | 5,2 | 5,6 | 6,6 |
| ផ.ស.ស.សម្រាប់មនុស្សម្នាក់ (ដុល្លារអាមេរិក) | 1 784 | 1 917 | 2 071 |
| អតិផរណា (អត្រាមធ្យមប្រចាំឆ្នាំ) | 5,3 | 2,5 | 2,5 |
| អត្រាប្តូរប្រាក់ (ដុល្លារអាមេរិក/ រៀល) | 4 090 | 4 065 | 4 065 |
| សមតុល្យគណនីចរន្ត (% នៃ ផ.ស.ស.) | -25,6 | -10,7 | -9,6 |
| ទុនបម្រុងអន្តរជាតិ (លានដុល្លារអាមេរិក) | 17 805 | 19 437 | 21 285 |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូល) | 6,1 | 6,9 | 6,6 |

*ប្រភព÷ ក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា សម្រាប់ឆ្នាំ ២០២២ និងការប៉ាន់ស្មានឆ្នាំ ២០២៣ និងការព្យាករឆ្នាំ ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ខែ ឧសភា ឆ្នាំ ២០២៣*

- **អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ** ត្រូវបានរំពឹងថានឹងរក្សាបានក្នុងរង្វង់ ២,៥% ក្នុងឆ្នាំ ២០២៤ ដោយសារការរំពឹងទុកនូវការវិលត្រលប់ទៅរកប្រក្រតីភាពវិញនៃថ្លៃប្រេងអន្តរជាតិ។ យ៉ាងណាមិញ ហានិភ័យដែលបង្កឡើងដោយភាពមិនប្រាកដប្រជាមួយចំនួន ដូចជាភាពកាន់តែតានតឹងនៃភូមិសាស្ត្រសេដ្ឋកិច្ច និងនយោបាយ អាចធ្វើឱ្យអត្រាអតិផរណាមានការហក់ឡើងមកវិញ ដែលស្តែងចេញពីកត្តាផ្គត់ផ្គង់។
- **អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក** ត្រូវបានរំពឹងថានឹងនៅបន្តមានស្ថិរភាពក្នុងរង្វង់ ៤ ០៦៥ រៀលក្នុងមួយដុល្លារអាមេរិកក្នុងឆ្នាំ ២០២៤ ដោយសារការបន្តអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុ។

## ២.២. កំណើនតាមវិស័យសំខាន់ៗ




តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជានៅក្នុងឆ្នាំ ២០២៤ ត្រូវបានទ្រទ្រង់ដោយ÷ **(ទី១)-វិស័យឧស្សាហកម្មត្រូវបានព្យាករថានឹងបន្តនិន្នាការកើនឡើងក្នុងរង្វង់ ៨,៥% ក្នុងឆ្នាំ ២០២៤ ពីប្រមាណ ៥,០% ក្នុងឆ្នាំ ២០២៣ ដោយសារការរំពឹងទុកការងើបឡើងវិញនៃអនុវិស័យកាត់ដេរ ស្របពេលដែលអនុវិស័យកម្មន្តសាលមិនមែនកាត់ដេរនៅបន្តរក្សាបានកំណើនរឹងមាំ ខណៈដែលអនុវិស័យសំណង់នៅបន្តមានកំណើនទាប។** អនុវិស័យកាត់ដេរ រំពឹងថានឹងមាននិន្នាការងើបឡើងវិញ ដោយសារការងើបឡើងវិញ នៃតម្រូវការសកល ជាពិសេសបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា រួមមាន សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ជាដើម។ ជាមួយគ្នានេះ, ការដាក់ចេញនូវ «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ, ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧**» ក៏ត្រូវបានរំពឹងថានឹងជួយជំរុញបរិយាកាសវិនិយោគ និងការប្រកួតប្រជែងបន្ថែមក្នុងអនុវិស័យនេះផងដែរ។ យ៉ាងណាមិញ, ភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពសេដ្ឋកិច្ចសកល ដែលនាំឱ្យមានភាពរង្គោះរង្គើដល់តម្រូវការខាងក្រៅ ជាពិសេសទីផ្សារសំខាន់ៗរបស់កម្ពុជា រួមមាន÷ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប អាចនឹងបង្កជាបច្ច័យអវិជ្ជមានដល់អនុវិស័យនេះផងដែរ។ អនុវិស័យកម្មន្តសាលមិនមែនកាត់ដេរ នៅបន្តរក្សាបានភាពល្អ ដែលមួយផ្នែកនឹងបន្តជំរុញដោយការរក្សាបានតុល្យភាពនៃផលិតកម្មដែលបម្រើឱ្យ

តម្រូវការក្នុងស្រុក និងមួយផ្នែកទៀត គាំទ្រដោយការរំពឹងទុកកំណើនល្អប្រសើរនៃផលិតកម្ម បម្រើឱ្យការនាំចេញ។ និន្នាការល្អនៃតម្រូវការខាងក្រៅ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី នឹងបន្តជំរុញកំណើននៃអនុវិស័យនេះ លើផ្នែកផលិតកម្មបម្រើការនាំចេញ ជាពិសេសទៅលើផលិតផលសំខាន់ៗ មួយចំនួនរួមមាន÷ បន្ទះសូឡា, សំបកកង់, និងស្បែកសត្វមានរោម ជាដើម។ ទន្ទឹមនេះ, ការដាក់ចេញនូវ «**ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា**» នឹងអាចរួមចំណែកបង្កើនបរិយាកាសវិនិយោគឱ្យកាន់តែមានភាពទាក់ទាញ និងប្រសើរជាងមុន។ ដោយឡែក អនុវិស័យសំណង់ ត្រូវបានរំពឹងថានឹងបន្តកំណើនទាបជាងនិន្នាការធម្មតាដោយសារការរំពឹងទុកងើបឡើងវិញយឺតនៃលំហូរទុនវិនិយោគពីបរទេស ជាពិសេសសម្រាប់សំណង់ថ្លៃខ្ពស់ ក៏ដូចជាសំណង់បម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ស្របពេលដែលសកម្មភាពសំណង់លំនៅឋានក៏ត្រូវបានរំពឹងថានៅបន្តរក្សាកំណើន ប៉ុន្តែស្ថិតក្នុងកម្រិតទាប។

**(ទី២)- វិស័យសេវាកម្ម ត្រូវបានព្យាករថានឹងបន្តនិន្នាការល្អ ក្នុងអត្រាកំណើន ៦,៩% ក្នុងឆ្នាំ ២០២៤ ពីមូលដ្ឋានល្អក្នុងរង្វង់ ៨,១% ក្នុងឆ្នាំ ២០២៣ ដោយសារការបន្តងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ជាពិសេសអនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន ដែលក៏នឹងមានផលជះជាវិជ្ជមានដល់វិស័យ-អនុវិស័យគាំទ្រផ្សេងៗទៀត រួមមាន អនុវិស័យលក់ដុំ-រាយ និងដឹកជញ្ជូនជាដើម។** អនុវិស័យ សណ្ឋាគារ និងភោជនីយដ្ឋាន បន្តនិន្នាការប្រសើរ ដោយសារការរំពឹងទុកការងើបឡើងវិញនៃភ្ញៀវទេសចរអន្តរជាតិ ស្របពេលដែលមានភ្ញៀវទេសចរជាតិក៏រំពឹងថានឹងបន្តកើនឡើង។ អនុវិស័យលក់ដុំ-រាយ រំពឹងថានឹងបន្តនិន្នាការកើនឡើង ដោយសារការរំពឹងទុកនូវការបន្តងើបឡើងវិញនូវចំណូលរបស់ប្រជាជន និងសកម្មភាពចាយវាយក្នុងស្រុក គួបផ្សំនិងការផ្លាស់ប្តូរតំរិយាបថនៃអាជីវកម្ម ក៏ដូចជាសកម្មភាពទិញ-លក់ពីបែបប្រពៃណី (Brick-And-Morta) ដោយជំនួសមកវិញនូវការប្រើប្រាស់ថ្នាលឌីជីថល ដែលការណ៍នេះនឹងបន្តជំរុញបន្ថែមទៀតដល់សកម្មភាពប្រើប្រាស់ក្នុងស្រុក ជារួម។ អនុវិស័យដឹកជញ្ជូន និងគមនាគមន៍រំពឹងថានឹងបន្តកើនឡើង គាំទ្រដោយការបន្តងើបឡើងនៃសកម្មភាពដឹកជញ្ជូនបម្រើឱ្យវិស័យទេសចរណ៍ និងពាណិជ្ជកម្ម ស្របពេលដែលសកម្មភាពគមនាគមន៍ក៏នៅបន្តរក្សានិន្នាការល្អប្រសើរ ដោយសារការបន្តកើនឡើងនូវការប្រើប្រាស់អ៊ីនធឺណិត និងឌីជីថលក្នុងអាជីវកម្ម និងជីវភាពប្រចាំថ្ងៃ ក្នុងគន្លងប្រក្រតីភាពថ្មី។ ទន្ទឹមនេះ ការដាក់ចេញ និងអនុវត្តនូវ «ក្របខ័ណ្ឌគោល-នយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥» នឹងបង្កើនការវិនិយោគលើ

ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងលើកកម្ពស់ការប្រើប្រាស់ឌីជីថលនៅកម្ពុជា។ យ៉ាងណាមិញ, អនុវិស័យអចលនទ្រព្យ រំពឹងថានឹងបន្តនិន្នាការកើនឡើង ប៉ុន្តែក្នុងល្បឿនទាប ដោយសារការរំពឹងទុកការបន្តងើបឡើងវិញយឺតនៃលំហូរទុនវិនិយោគពីបរទេស និងកំណើនទាបនៃសកម្មភាពទិញ-លក់អចលនទ្រព្យ ជារួម។

**(ទី៣)-វិស័យកសិកម្ម រំពឹងថានឹងបន្តសម្រេចបានកំណើនល្អ ក្នុងរង្វង់ ១,១% ក្នុងឆ្នាំ ២០២៤ ធៀបនឹង ០,៩% ក្នុងឆ្នាំ ២០២៣ ដោយសារការបន្តនិន្នាការល្អនៃអនុវិស័យដំណាំ និងការបន្តងើបឡើងវិញនៃអនុវិស័យនេសាទ ខណៈដែលអនុវិស័យចិញ្ចឹមសត្វនៅបន្តមានស្ថិរភាព។** អនុវិស័យដំណាំបន្តនិន្នាការល្អ ដោយសារការរំពឹងទុកនូវកំណើននៃផលិតកម្មដែលជំរុញដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងៗ រួមមាន «កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន», «កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ» និង «កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)» ជាដើម គួបផ្សំនឹងការបង្កើនការវិនិយោគរបស់រាជរដ្ឋាភិបាលតាមរយៈការបន្តផ្តល់ការលើកទឹកចិត្តផ្នែកពន្ធសម្រាប់ការនាំចូលវត្ថុធាតុដើមកសិកម្ម និងការផ្តល់ហិរញ្ញប្បទានក្នុងការជំរុញផលិតកម្មក្នុងស្រុក។ អនុវិស័យចិញ្ចឹមសត្វនៅបន្តរក្សាបានស្ថិរភាព ដោយសារការរំពឹងទុកនូវការកើនឡើងនៃផលិតកម្ម ដែលជំរុញដោយតម្រូវការក្នុងស្រុកសម្រាប់បម្រើការបន្តងើបឡើងវិញនៃវិស័យទេសចរណ៍ គួបផ្សំនឹងវិធានការអន្តរាគមន៍របស់រាជរដ្ឋាភិបាល និងការអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍នានា។ អនុវិស័យនេសាទនឹងបន្តងើបឡើងវិញក្រោមការរំពឹងទុកនូវកំណើនផលចាប់ទឹកសាប ដែលបន្តស្តារឡើងវិញដោយការដាក់ចេញនូវគោលនយោបាយបង្ក្រាបបទល្មើសនេសាទ គួបផ្សំនឹងការងើបឡើងបណ្តើរៗមកវិញនៃផលិតកម្មវារីវប្បកម្ម ព្រមទាំងការជួយជ្រោមជ្រែងពីរាជរដ្ឋាភិបាល តាមរយៈការដោះស្រាយបញ្ហាប្រឈមជារចនាសម្ព័ន្ធ, ការគាំទ្រផ្នែកហិរញ្ញប្បទាន, ការផ្សព្វផ្សាយបច្ចេកទេស និងការប្រើប្រាស់ពូជត្រីប្រកបដោយប្រសិទ្ធភាពខ្ពស់ និងគុណភាព។

## ជំពូក ៣. ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៤

ផ្អែកលើមូលដ្ឋានក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងការវិវត្តជាក់ស្តែងនៃស្ថានភាពហិរញ្ញវត្ថុសាធារណៈ, រាជរដ្ឋាភិបាលប្រកាន់យកនូវជំហាននៃការអនុវត្ត "គោលជំហរពង្រឹងប្រសិទ្ធភាពថវិកា" (Fiscal Consolidation Stance) នៅក្នុងឆ្នាំ ២០២៤ សំដៅជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ក្នុងបរិការណ៍នៃការចាកចេញពីវិបត្តិកូវីដ-១៩ និងលើកកម្ពស់កិច្ចអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ក្នុងន័យនេះ ក្របខ័ណ្ឌថវិកាឆ្នាំ ២០២៤ ត្រូវបានកំណត់ដូចខាងក្រោម÷

| សូចនាករថវិកា | ២០២២ | | ២០២៣ | ២០២៤ |
|---|---|---|---|---|
| | ច្បាប់ | អនុវត្ត | ច្បាប់ | គ្រោង |
| **ចំណូលសរុបថវិការដ្ឋ (% ផ.ស.ស.)** | 27,01 | 28,84 | 28,11 | 22,74 |
| **ចំណូលក្នុងប្រទេសថវិការដ្ឋ (% ផ.ស.ស.)** | 21,15 | 22,79 | 22,41 | 22,25 |
| -ចំណូលចរន្តថវិការដ្ឋ (% ផ.ស.ស.) | 20,08 | 22,70 | 21,53 | 21,90 |
| **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ (% ផ.ស.ស.)** | 28,69 | 26,76 | 29,97 | 25,96 |
| -ចំណាយចរន្តថវិការដ្ឋ (% ផ.ស.ស.) | 17,23 | 16,51 | 17,53 | 18,11 |
| **អតិរេកចរន្ត (% ផ.ស.ស.)** | 2,84 | 6,18 | 4,00 | 3,79 |
| **ឱនភាពសរុប (% ផ.ស.ស.)** | -7,53 | -4,03 | -7,56 | -3,22 |

- **ចំណូលសរុបថវិការដ្ឋ** ត្រូវបានគ្រោង ២២,៧៤% នៃ ផសស ស្មើនឹងចំនួន ៣២ ៥០៨ ៩៤០ លានរៀល។
- **ចំណាយសរុបថវិការដ្ឋ** ត្រូវបានគ្រោង ២៥,៩៦% នៃ ផសស ស្មើនឹងចំនួន ៣៧ ១១០ ៤០៤ លានរៀល។
- **អតិរេកថវិកាចរន្ត** អាចរក្សាបានក្នុងកម្រិតប្រមាណ ៣,៧៩% នៃ ផសស។
- **ឱនភាពថវិកាសរុប** ស្មើនឹង -៣,២២% នៃ ផសស។ ដូចនេះ, រាជរដ្ឋាភិបាលមាន**តម្រូវការហិរញ្ញប្បទាន**ទំហំ ៣,២២% នៃ ផ.ស.ស ដើម្បី**បំពេញឱនភាពថវិកាជាតិ** ព្រមទាំងមានតម្រូវការហិរញ្ញប្បទានទំហំ ១,៤៨% នៃ ផ.ស.ស. ស្មើនឹង ២ ១១៥ ប៊ីលានរៀល សម្រាប់ការទូទាត់ប្រាក់ខ្ចី ដើម្បីរំលស់បំណុលសាធារណៈក្នុងប្រទេស និងក្រៅប្រទេសផងដែរ ស្របតាមវិធាន និងនីតិវិធីថ្មីនៃការទូទាត់ប្រាក់ខ្ចី ដែលបានកំណត់នៅក្នុងច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ឆ្នាំ ២០២៣។ ជាសរុប, សម្រាប់ថវិកាឆ្នាំ ២០២៤ រាជរដ្ឋាភិបាល មានតម្រូវការហិរញ្ញប្បទានក្នុងទំហំ ៨,៧០% នៃ ផ.ស.ស. ដែលនឹងត្រូវបានគាំទ្រហិរញ្ញប្បទានក្នុងប្រទេស តាមរយៈការបោះផ្សាយមូលបត្ររដ្ឋ ក្នុងទំហំ ៤៤០ ប៊ីលានរៀល, សមមូលនឹងប្រមាណ ១០៨ លានដុល្លារអាមេរិក និង ហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ ៨,៣៩% នៃ ផ.ស.ស. ក្នុងនោះមាន÷ មូលនិធិទ្រទ្រង់ថវិកាទំហំ ០,៤៩% នៃ ផ.ស.ស. និង ថវិកាវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសទំហំ ៣,៩០% នៃ ផ.ស.ស.។

<u>ឯកតា លានរៀល</u>



### ៣.១. ស្ថានភាពចំណូលថវិការដ្ឋ

ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលសរុបថវិការដ្ឋ ឬចំណូលសរុបថវិកាជាតិ ឱ្យស្មើនឹង **៣២ ៥០៨ ៩៤០ លានរៀល** ក្នុងនោះ ចំណូលចរន្តថវិការដ្ឋឱ្យស្មើនឹង **៣១ ៣០៤ ៦១១ លានរៀល** (ដែលរួមមាន ចំណូលសារពើពន្ធ **២៧ ៩៧៣ ៧៨២** លានរៀល និង ចំណូលមិនមែនសារពើពន្ធ **៣ ៣៣០ ៨២៩ លានរៀល**)។ ដោយឡែក, ចំណូលផ្សេងៗ ត្រូវបានគ្រោង**១ ២០៤ ៣២៩** លានរៀល, ត្រូវជា ០,៨៤% នៃ ផ.ស.ស.; ក្នុងនោះចំណូលផ្សេងៗក្រៅប្រទេសស្មើនឹងប្រមាណ ១,៩% នៃចំណាយសរុបថវិការដ្ឋ ឆ្នាំ២០២៣ ប៉ុណ្ណោះ។

| ចំណូលថវិកា (ឯកតាលានរៀល) | ២០២៣ ច្បាប់ | ២០២៣ % ផ.ស.ស. | ២០២៤ គ្រោង | ២០២៤ % ផ.ស.ស. | % កំណើន |
|---|---|---|---|---|---|
| **ចំណូលសរុបថវិការដ្ឋ** | **36.767.670** | **28,11%** | **32.508.940** | **22,74%** | **-11,6%** |
| • *ថ្នាក់ជាតិ* | 34.165.163 | 26,12% | 29.895.980 | 20,91% | -12,5% |
| • *ថ្នាក់ក្រោមជាតិ* | 2.602.507 | 1,99% | 2.612.960 | 1,83% | 0,4% |
| **១. ចំណូលចរន្តថវិការដ្ឋ** | **28.166.935** | **21,53%** | **31.304.611** | **21,90%** | **11,1%** |
| ***ក. ចំណូលសារពើពន្ធថវិការដ្ឋ*** | **25.594.274** | **19,57%** | **27.973.782** | **19,57%** | **9,3%** |
| - *ថ្នាក់ជាតិ* | 23.421.924 | 17,91% | 25.759.061 | 18,02% | 10% |
| - *ថ្នាក់ក្រោមជាតិ* | 2.172.350 | 1,66% | 2.214.721 | 1,55% | 2% |
| ***ខ. ចំណូលមិនមែនសារពើពន្ធថវិការដ្ឋ*** | **2.572.661** | **1,97%** | **3.330.829** | **2,33%** | **29,5%** |
| - *ថ្នាក់ជាតិ* | 2.142.504 | 1,64% | 3.077.416 | 2,15% | 43,6% |
| - *ថ្នាក់ក្រោមជាតិ* | 430.157 | 0,33% | 253.413 | 0,18% | -41,1% |
| **២. ចំណូលផ្សេងៗ** | **8.600.735** | **6,58%** | **1.204.329** | **0,84%** | **-86,0%** |
| ***- ថវិកាថ្នាក់ជាតិ*** | **8.600.735** | **6,58%** | **1.059.503** | **0,74%** | **-87,7%** |
| • *ក្នុងប្រទេស* | 1.144.812 | 0,88% | 363.126 | 0,25% | -68,3% |
| • *ក្រៅប្រទេស* | 7.455.923 | 5,7% | 696.377 | 0,49% | -90,7% |
| ***- ថវិកាថ្នាក់ក្រោមជាតិ*** | - | - | **144.826** | **0,10%** | - |

## ៣.២. ស្ថានភាពចំណាយថវិការដ្ឋ

សម្រាប់ឆ្នាំ ២០២៤ ចំណាយសរុបថវិការដ្ឋ ឬ ចំណាយសរុបថវិកាជាតិ ត្រូវបានគ្រោងចំនួន **៣៧ ១១០ ៤០៤ លានរៀល**, ត្រូវជា **២៥,៩៦%** នៃ ផ.ស.ស., ថយចុះ ៥,៣% ធៀបនឹងច្បាប់ឆ្នាំ ២០២៣, ដែលក្នុងនោះ÷ **(១)-ចំណាយចរន្តថវិការដ្ឋ**មានចំនួន **២៥ ៨៨៣ ៧៩៨ លានរៀល**, ត្រូវជា **១៨,១១%** នៃ ផ.ស.ស., **និង (២)-ចំណាយមូលធនថវិការដ្ឋ**មានចំនួន **១១ ២២៦ ៦០៦ លានរៀល**, ត្រូវជា **៧,៨៥%** នៃ ផ.ស.ស.។

| ចំណាយថវិកា | ២០២៣ | | ២០២៤ | | % |
|---|---|---|---|---|---|
| (ឯកតាលានរៀល) | ច្បាប់ | % ផ.ស.ស. | គ្រោង | % ផ.ស.ស. | កំណើន |
| **ចំណាយសរុបថវិការដ្ឋ ឬ ថវិកាជាតិ** | **39.206.205** | **29,97%** | **37.110.404** | **25,96%** | **-5,3%** |
| • *ថ្នាក់ជាតិ* | 36.603.698 | 27,98% | 34.497.444 | 24,13% | -5,8% |
| • *ថ្នាក់ក្រោមជាតិ* | 4.061.797 | 3,11% | 4.331.871 | 3,03% | 6,6% |
| **១. ចំណាយចរន្តថវិការដ្ឋ** | **22.928.932** | **17,53%** | **25.883.798** | **18,11%** | **12,9%** |
| ***១.១. ថ្នាក់ជាតិ*** | **20.839.425** | **15,93%** | **23.805.838** | **16,65%** | **14,2%** |
| *•បន្ទុកបុគ្គលិក* | 9.555.197 | 7,30% | 10.254.967 | 7,17% | 7,3% |
| *•ក្រៅបន្ទុកបុគ្គលិក* | 11.284.229 | 8,63% | 13.550.871 | 9,48% | 20,1% |
| ***១.២. ថ្នាក់ក្រោមជាតិ*** | **3.548.797** | **2,71%** | **3.796.871** | **2,66%** | **7,0%** |
| *•បន្ទុកបុគ្គលិក* | 879.914 | 0,67% | 933.394 | 0,65% | 6,1% |
| *•ក្រៅបន្ទុកបុគ្គលិក* | 2.668.883 | 2,04% | 2.863.476 | 2,00% | 7,3% |
| **២. ចំណាយមូលធនថវិការដ្ឋ** | **16.277.273** | **12,44%** | **11.226.606** | **7,85%** | **-31,0%** |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស* | 8.243.971 | 6,30% | 5.018.730 | 3,51% | -39,1% |
| *+ ក្នុងនោះចំណាយមូលធនថ្នាក់ក្រោមជាតិ* | 513.000 | 0,39% | 535.000 | 0,37% | 4,3% |
| *- ការទូទាត់ប្រាក់ខ្ចី* | 1.859.887 | 1,42% | - | - | - |
| *-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស* | 6.173.415 | 4,72% | 6.207.876 | 4,34% | 0,6% |

### ៣.៣. ថវិកាថ្នាក់ជាតិ

| ចំណាយថវិកាតាមវិស័យ (ឯកតាលានរៀល) | ២០២៣ ច្បាប់ | ២០២៣ % ផ.ស.ស. | ២០២៤ គ្រោង | ២០២៤ % ផ.ស.ស. | % កំណើន |
|---|---|---|---|---|---|
| **១. វិស័យរដ្ឋបាលទូទៅ** | **3.079.429** | **2,35%** | **3.124.359** | **2,19%** | **1,5%** |
| **ក. ចំណាយចរន្ត** | **2.841.034** | **2,17%** | **2.986.962** | **2,09%** | **5,1%** |
| -បន្ទុកបុគ្គលិក | 762.262 | 0,58% | 864.292 | 0,60% | 13,4% |
| -ក្រៅបន្ទុកបុគ្គលិក | 2.078.772 | 1,59% | 2.122.670 | 1,48% | 2,1% |
| **ខ. ចំណាយមូលធន** | **238.395** | **0,18%** | **137.397** | **0,10%** | **-42,4%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | - | - | - | - | - |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 238.395 | 0,18% | 137.397 | 0,10% | -42,4% |
| **២.វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** | **5.215.546** | **3,99%** | **5.540.736** | **3,88%** | **6,2%** |
| **ក. ចំណាយចរន្ត** | **5.101.874** | **3,90%** | **5.453.571** | **3,81%** | **6,9%** |
| -បន្ទុកបុគ្គលិក | 4.184.410 | 3,20% | 4.453.042 | 3,11% | 6,4% |
| -ក្រៅបន្ទុកបុគ្គលិក | 917.464 | 0,70% | 1.000.529 | 0,70% | 9,1% |
| **ខ. ចំណាយមូលធន** | **113.672** | **0,09%** | **87.165** | **0,06%** | **-23,3%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 30.000 | 0,02% | 34.320 | 0,02% | 14,4% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 83.672 | 0,06% | 52.845 | 0,04% | -36,8% |
| **៣. វិស័យសង្គមកិច្ច** | **8.989.718** | **6,87%** | **10.149.947** | **7,10%** | **12,9%** |
| **ក. ចំណាយចរន្ត** | **7.927.353** | **6,06%** | **9.211.461** | **6,44%** | **16,2%** |
| -បន្ទុកបុគ្គលិក | 4.027.946 | 3,08% | 4.281.856 | 3,00% | 6,3% |
| -ក្រៅបន្ទុកបុគ្គលិក | 3.899.408 | 2,98% | 4.929.606 | 3,45% | 26,4% |
| **ខ. ចំណាយមូលធន** | **1.062.365** | **0,81%** | **938.486** | **0,66%** | **-11,7%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 130.000 | 0,10% | 150.000 | 0,10% | 15,4% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 932.365 | 0,71% | 788.486 | 0,55% | -15,4% |
| **៤. វិស័យសេដ្ឋកិច្ច** | **7.046.053** | **5,39%** | **7.530.118** | **5,27%** | **6,9%** |
| **ក. ចំណាយចរន្ត** | **1.582.070** | **1,21%** | **1.755.970** | **1,23%** | **11,0%** |
| -បន្ទុកបុគ្គលិក | 580.579 | 0,44% | 655.777 | 0,46% | 13,0% |
| -ក្រៅបន្ទុកបុគ្គលិក | 1.001.491 | 0,77% | 1.100.193 | 0,77% | 9,9% |
| **ខ. ចំណាយមូលធន** | **5.463.983** | **4,18%** | **5.774.148** | **4,04%** | **5,7%** |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | 545.000 | 0,42% | 545.000 | 0,38% | 0,00% |
| -វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | 4.918.983 | 3,76% | 5.229.148 | 3,66% | 6,3% |

### ៣.៣.១. ចំណាយលើបន្ទុកបុគ្គលិក

ចំណាយលើបន្ទុកបុគ្គលិក ត្រូវបានគ្រោងចំនួន **១០ ២៥៤ ៩៦៧ លានរៀល** សម្រាប់÷ **(១)-ការជ្រើសរើសក្របខ័ណ្ឌថ្មី** ជំនួសអ្នកចូលនិវត្តន៍ក្នុងឆ្នាំ ២០២៣ ជូនក្រសួង-ស្ថាប័ន សម្រាប់ឆ្នាំ ២០២៤ ដែលក្រសួងមុខងារសាធារណៈ នឹងកំណត់នាពេលខាងមុខ; **(២)-ការដំឡើងបៀវត្សមូលដ្ឋានជូនមន្ត្រីរាជការ**; និង **(៣)-ការដំឡើងប្រាក់បំណាច់មុខងារ**។ ក្នុងគោលបំណងបន្តអនុវត្តគោលនយោបាយដំឡើងបៀវត្សអប្បបរមាជូនមន្ត្រីរាជការ, បៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នៅឆ្នាំ ២០២៤ នឹងត្រូវបានដំឡើងចំនួន ៥%, ហើយប្រាក់បំណាច់មុខងារនឹងត្រូវបានដំឡើងតាមកម្រិត ដូចខាងក្រោម÷

- ផ្តល់បន្ថែមជូន **២២ ៥០០ រៀល** សម្រាប់មន្ត្រីរាជការស៊ីវិលដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី **១ ១៣០ ០០០ រៀល** ចុះក្រោម និងបន្ថែមជូន **២០ ០០០ រៀល** សម្រាប់មន្ត្រីរាជការដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី **១ ១៣០ ១០០ រៀល** ឡើងទៅ
- ផ្តល់បន្ថែមជូន **២៥ ០០០ រៀល** សម្រាប់មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារ ក្នុងកម្រិតចាប់ពី **៩៦០ ០០០ រៀល** ចុះក្រោម និងបន្ថែមជូន **២០ ០០០ រៀល** សម្រាប់មន្ត្រីនគរបាលជាតិ និងយោធិន ដែលមានប្រាក់បំណាច់មុខងារក្នុងកម្រិតចាប់ពី **៩៦០ ១០០ រៀល** ឡើងទៅ។

ដូចនេះ, ស្ថានភាពបៀវត្សអប្បបរមារបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ នៅឆ្នាំ ២០២៤ នឹងប្រែប្រួលដូចខាងក្រោម÷

- **បៀវត្សមន្ត្រីរាជការស៊ីវិល** នឹងត្រូវបានដំឡើងពីចំនួន **១ ៣០០ ០០០** រៀល នៅឆ្នាំ ២០២៣ ដល់ប្រមាណ **១ ៣៥៦ ៩៥០** រៀល;
- **បៀវត្សគ្រូបង្រៀន និងគ្រូពេទ្យ** នឹងត្រូវបានដំឡើងពីចំនួន **១ ៤០០ ០០០** រៀល នៅឆ្នាំ ២០២៣ ដល់ប្រមាណ **១ ៤៥៦ ៩៥០** រៀល;
- **បៀវត្សនគរបាលជាតិ (ពលបាលត្រី)** នឹងត្រូវបានដំឡើងពី ១ ៣៨៤ ៤៧៧ រៀល (ដោយគិតបញ្ចូលទាំងរបបអង្គរ) នៅឆ្នាំ ២០២៣ ដល់ប្រមាណ **១ ៤៤៣ ៩២៧ រៀល** (ដោយគិតបញ្ចូលទាំងរបបអង្គរ);
- **បៀវត្សយោធិន (ពលទោ)** នឹងត្រូវបានដំឡើងពី ១ ២៥១ ០០០ រៀល (ដោយមិនទាន់គិតបញ្ចូលរបបអង្គរ) នៅឆ្នាំ២០២៣ ដល់ប្រមាណ១ ៣០៦ ៥៥០រៀល (ដោយមិនទាន់គិតបញ្ចូលរបបអង្គរ) ហើយបើគិតបញ្ចូលទាំងរបបអង្គរ ត្រូវជាប្រមាណ ១ ៣៦៥ ០២៧ រៀល។

ចំពោះ **ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា** នឹងត្រូវបានដំឡើងពី **៧១ ម៉ឺនរៀល** ទៅដល់ **៧៧ ម៉ឺនរៀល**ផងដែរ នៅក្នុងឆ្នាំ ២០២៤។

ទន្ទឹមនេះ, រាជរដ្ឋាភិបាលនឹងដំឡើងប្រាក់សោធន ព្រមទាំងនឹងធ្វើសមាហរណកម្មប្រាក់សោធនតាមប្រព័ន្ធបៀវត្សចាស់ ចូលទៅក្នុងប្រព័ន្ធបៀវត្សថ្មី ដើម្បីដោះស្រាយបញ្ហាគម្លាតរវាងអ្នកចូលនិវត្តចាស់ និង ថ្មី ឱ្យបានចប់នៅក្នុងឆ្នាំ ២០២៤ ផងដែរ។ ជាក់ស្ដែង, តាមរយៈវិធានការនេះ, ថវិកាចំនួន **១៨១ ប៊ីលានរៀល** ត្រូវបានគ្រោងសម្រាប់**ការដំឡើងប្រាក់សោធន និង កាត់បន្ថយគម្លាត**នេះនៅឆ្នាំ ២០២៣ និង ថវិកាចំនួន **១០០ ប៊ីលានរៀល** ត្រូវបានគ្រោងសម្រាប់ឆ្នាំ ២០២៤។ ដូចនេះ, **ប្រាក់សោធនអប្បបរមាប្រចាំខែ**របស់ អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន(អតីតយោធិន និង អតីតមន្ត្រីនគរបាលជាតិ) ត្រូវបានដំឡើងពី **៧៧ ម៉ឺនរៀល** នៅឆ្នាំ ២០២៣ ដល់ **៨២,៥ ម៉ឺនរៀល** នៅឆ្នាំ ២០២៤។

កាលបរិច្ឆេទសម្រាប់ការអនុវត្តការដំឡើងប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បំណាច់មុខងារ ជូនដល់មន្ត្រីរាជការ ព្រមទាំងការដំឡើងប្រាក់ឧបត្ថម្ភប្រចាំខែ សម្រាប់មន្ត្រីជាប់កិច្ចសន្យា និងការដំឡើងប្រាក់សោធនប្រចាំខែជូនអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ក៏ដូចជាប្រាក់ឧបត្ថម្ភផ្សេងៗ នឹងត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល នាពេលខាងមុខ។

លើសពីនេះ, សម្រាប់ឆ្នាំ ២០២៤ នេះដែរ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំនួន **៤៩២ ប៊ីលានរៀល** សមមូលនឹងប្រមាណ **១២០ លានដុល្លារអាម៉េរិក** ដោយឡែកផ្សេងទៀត សម្រាប់ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ ដោយផ្ដោតជាសំខាន់លើការពង្រឹងគុណភាព ប្រសិទ្ធភាព និងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន តាមរយៈការលើកទឹកចិត្តចំពោះមន្ត្រីដែលមានគុណវុឌ្ឍិ ដែលកិច្ចការនេះនឹងស្ថិតក្រោមការដឹកនាំផ្ទាល់ ពីសំណាក់ប្រមុខរាជរដ្ឋាភិបាល។

ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏បានគ្រោងថវិកាចំនួន **៩៥ ប៊ីលានរៀល** សម្រាប់ការថែទាំសុខភាពមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ និងនិវត្តជន ព្រមទាំងបានបន្តគ្រោងថវិកាចំនួន **៦ ប៊ីលានរៀល** សម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារជូនមន្ត្រីសាធារណៈផងដែរ។

### ៣.៣.២. ចំណាយមិនមែនបន្ទុកបុគ្គលិក

ត្រូវបានគ្រោងចំនួន **១៣ ៥៥០ ៨៧១ លានរៀល**, មានសមាមាត្រស្មើនឹង **៥៦,៩%** នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា **៩,៤៨%** នៃ ផ.ស.ស., គឺកើនឡើង **២០,១%** ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២៣។ ការគ្រោងកើនឡើងនេះ គឺដើម្បីបំពេញសេចក្ដីត្រូវការចាំបាច់របស់ក្រសួង-ស្ថាប័ន ក្នុងការអនុវត្តការងារអាទិភាពរបស់ខ្លួន និងការងារកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល, ជាពិសេសផ្ដោតលើការគាំទ្រកម្មវិធីគោលនយោបាយអាទិភាពចំនួន ៦ របស់រាជរដ្ឋាភិបាលនីតិកាល

ទី ៧ នៃរដ្ឋសភា រួមមាន÷ (១)-ការពង្រីកសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្រប់ដណ្ដប់សុខភាពជាសកល; (២)-ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជន មកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស; (៣)-ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គមសម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និងគ្រាមានគ្រោះអាសន្ន; (៤)-ការអនុវត្តយុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ; (៥)-យន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗក្នុងកម្រិតសមរម្យ; និង (៦)-ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ- សង្កាត់ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស។ លើសពីនេះ, ថវិកាក៏ត្រូវបានវិភាជសម្រាប់ការអនុវត្តវិធានការគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមជាអាទិភាព រួមមាន÷ ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ, ការលើកកម្ពស់គុណភាពអប់រំ, ការលើកកម្ពស់គុណភាពសេវាសុខាភិបាល, ការពង្រឹងការអនុវត្តគោលនយោបាយ «ភូមិ- ឃុំ- សង្កាត់ មានសុវត្ថិភាព», ព្រមទាំងការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវបានវិភាជន៍តាមវិស័យ គ្របដណ្ដប់លើក្រសួងស្ថាប័នទាំង ៣៩ ហើយនៅកម្រិតក្រសួង- ស្ថាប័ននីមួយៗវិញ ត្រូវបានធ្វើការវិភាជបន្តទៅតាមកម្មវិធី អនុកម្មវិធី រហូតដល់ចង្កោមសកម្មភាព តាមរយៈការឆ្លុះបញ្ចាំងយ៉ាងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា ដោយផ្អែកលើតម្រូវការ និងអាទិភាពចាំបាច់ ដូចតទៅ÷

**<u>ចំណាយវិស័យរដ្ឋបាលទូទៅ÷</u>**

- ការគាំទ្រដល់**ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី ៥** និង ការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី- ខេត្ត, ក្រុង- ស្រុក- ខណ្ឌ អាណត្តិទី ៤;
- ការគាំទ្រដល់ការអនុវត្តការងារ និងតួនាទីរបស់ស្ថាប័ននីតិបញ្ញត្តិ;
- ការគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការទូត និងកិច្ចសហប្រតិបត្តិការអន្តរជាតិ;
- ការគាំទ្រដល់ការងារសម្របសម្រួលលើកិច្ចការទូទៅរបស់រាជរដ្ឋាភិបាល និងការងារជំនាញផ្សេងៗរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី;
- ការគាំទ្រដល់ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ- ដំណាក់កាលទី ១;
- ការបន្តធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ និងប្រព័ន្ធស្វ័យប្រវត្តិកម្មគយ;

- ការគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ជាពិសេសការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ និង ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ;
- ការបន្តគាំទ្រ និងពង្រឹងការងារសម្របសម្រួល តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ និងការអនុវត្តច្បាប់ស្តីពីវិនិយោគ;
- ការគាំទ្រដល់ការត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៥-២០២៥ រួមទាំង ការលើកស្ទួយ និងជំរុញវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុឱ្យកាន់តែរីកចម្រើន;
- ការជំរុញ និងការគាំទ្រដល់ធុរកិច្ចថ្មី, សហគ្រិនភាព, ថ្នាលឌីជីថល, និងសេដ្ឋកិច្ចនវានុវត្តន៍;
- ការបន្តគាំទ្រដល់ការពង្រឹងការគ្រប់គ្រងវិស័យសំណង់, ការរៀបចំប្លង់គោល, និងនគរូបនីយកម្ម;
- ការបន្តការគាំទ្រដល់ការចុះបញ្ជី និងការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ ដីឯកជន និងដីសហគមន៍;
- ការបន្តគាំទ្រដល់ការដោះស្រាយទំនាស់ដីធ្លី និងការបែងចែកដីសម្បទានសង្គមកិច្ច;
- ការបន្តគាំទ្រដល់ការចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ;
- ការបន្តគាំទ្រដល់សកម្មភាពបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឆ្ពោះទៅរកកម្ពុជាគ្មានគ្រាប់មីននៅឆ្នាំ ២០២៥ ក្រោមទិសស្លោក **ផ្តល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម**;
- ការបន្តគាំទ្រដល់វេទិកាសម្ព័ន្ធសង្គមស៊ីវិល ក្នុងកិច្ចអភិវឌ្ឍប្រទេស និងការលើកស្ទួយសិទ្ធិមនុស្ស;
- ការគាំទ្រដល់ការអភិវឌ្ឍ ការពង្រឹង និងពង្រីកប្រព័ន្ធស្ថិតិជាតិ និង;
- ការបន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

**<u>ចំណាយវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ÷</u>**

- ការបន្តផ្តោតការយកចិត្តទុកដាក់លើជីវភាពនិងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ;
- ការបន្តគាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ;

- ការបន្តគាំទ្រដល់ការផលិតលិខិតឆ្លងដែន ការផលិតអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ព្រមទាំងការរៀបចំប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យព្រំដែន;
- បន្តគាំទ្រដល់កិច្ចការសន្តិសុខជាតិ, សណ្តាប់ធ្នាប់សាធារណៈ, សកម្មភាពការងារកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍, ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការជួញដូរមនុស្ស ស្ត្រី និងកុមារ;
- ការបន្តគាំទ្រដល់ការពង្រឹងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព";
- ការបន្តគាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ;
- ការបន្តគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ;
- ការបន្តគាំទ្រការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌តាមរយៈការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, ការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស, និងការត្រួតពិនិត្យ និងការដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ;
- ការបន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

**<u>ចំណាយវិស័យសង្គមកិច្ច៖</u>**

- ការបន្តគាំទ្រដល់ការពង្រឹងនិងពង្រីកការទទួលបានសេវាអប់រំ និងការលើកកម្ពស់គុណភាពអប់រំ រួមទាំង ការបន្តគាំទ្រដល់មត្តេយ្យសិក្សាសហគមន៍ និងការអនុវត្តកម្មវិធីផ្តល់អាហារតាមសាលារៀន, ការបន្តគាំទ្រដល់ការផ្តល់ការលើកទឹកចិត្តដល់គ្រូបង្រៀនល្អ និងនាយកសាលាល្អ, ការបន្តគាំទ្រដល់ការពង្រឹង និងពង្រីកសាលារៀនជំនាន់ថ្មី នៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា, និងការបន្តគាំទ្រដល់ការលើកកម្ពស់វិស័យកីឡាជាតិ;
- ការបន្តគាំទ្រដល់ការអភិវឌ្ឍជំនាញ និងវិស័យការងារ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ;
- ការបន្តគាំទ្រដល់ការលើកកម្ពស់គុណភាពសេវាសុខាភិបាល និងការពង្រីកការទទួលបានសេវាថែទាំសុខភាព ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ពិសេសសម្រាប់ប្រជាជនក្រីក្រ ក្រុមជនងាយរងគ្រោះ ស្ត្រី និងកុមារ រួមទាំងការបន្តគាំទ្រសម្រាប់ការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លងជាយថាហេតុ, ការបន្តផ្តល់ថវិកាគាំទ្រកម្មវិធីមូលនិធិសមធម៌ ដើម្បីផ្តល់សេវាព្យាបាលដោយឥត

គិតថ្លៃជូនដល់ប្រជាជន ក្រីក្រ ប្រជាពលរដ្ឋងាយរងហានិភ័យ និងកម្មករនិយោជិតក្រៅប្រព័ន្ធ, និងការបន្តគាំទ្រដល់ប្រតិបត្តិការមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាពទូទាំងប្រទេស;

- ការបន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ ឆ្នាំ;
- ការបន្តផ្តល់របបសន្តិសុខសង្គមរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន;
- ការបន្តគាំទ្រដល់មូលនិធិមន្ទីរពេទ្យគន្ធបុប្ផាកម្ពុជា;
- ការបន្តផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រ និងចាស់ជរានៅតាមសហគមន៍;
- ការបន្តឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត និងមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា;
- ការបន្តគាំទ្រដល់ការការពារ និងអភិរក្សធនធានធម្មជាតិ;
- ការបន្តគាំទ្រដល់ការទប់ស្កាត់អំពើហឹង្សាលើស្ត្រី និងកុមារ;
- ការបន្តគាំទ្រដល់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ និង;
- ការបន្តគាំទ្រដល់សុខដុមនីយកម្មសាសនានៅកម្ពុជា។

**<u>ចំណាយវិស័យសេដ្ឋកិច្ច៖</u>**

- ការបន្តគាំទ្រដល់ការលើកកម្ពស់ផលិតភាព និងបច្ចេកទេសកសិកម្ម;
- ការបន្តគាំទ្រដល់ការជំរុញការចិញ្ចឹមសត្វតាមបច្ចេកទេស និងការទប់ស្កាត់ជំងឺឆ្លង;
- ការបន្តគាំទ្រដល់ការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច, ការបង្ការទប់ស្កាត់, និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល;
- ការបន្តគាំទ្រដល់ការអភិវឌ្ឍចម្ការឈើដាំ និងរុក្ខកម្ម និងការស្តារព្រៃឈើឡើងវិញ និងសង្គ្រោះសត្វព្រៃ;
- ការបន្តគាំទ្រដល់ការជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ និងការជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត និងទឹកជំនន់;
- ការបន្តគាំទ្រដល់ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ;
- ការបន្តគាំទ្រដល់ការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ;
- ការបន្តគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ;

- ការបន្តគាំទ្រការអភិវឌ្ឍផលិតផលទេសចរណ៍ និងការពង្រឹងគុណភាពសេវាទេសចរណ៍
- ការបន្តការគាំទ្រដល់ការស្វែងរកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា;
- ការបន្តគាំទ្រដល់ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ;
- ការបន្តគាំទ្រដល់ការអភិវឌ្ឍវិស័យទូរគមនាគមន៍; និង
- ការបន្តគាំទ្រដល់ការពង្រឹងយន្តការអភិវឌ្ឍន៍សហគ្រាសមីក្រូ តូច និងមធ្យម ព្រមទាំងការអនុវត្តយុទ្ធសាស្ត្រស្ដីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ។

**ព័ត៌មានបន្ថែមសម្រាប់ទំហំចំណាយថវិកាសរុប (ចំណាយចរន្ត និងចំណាយមូលធនក្នុងប្រទេស និងក្រៅប្រទេស) របស់ក្រសួង ស្ថាប័ន មានក្នុងតារាងឧបសម្ព័ន្ធទី ៣៩**

### ៣.៣.៣. ចំណាយមូលធនថ្នាក់ជាតិ

ត្រូវបានគ្រោងចំនួន **១០ ៦៩១ ៦០៦ លានរៀល**, មានសមាមាត្រស្មើនឹង **៣០,១%** នៃចំណាយសរុបថវិកាថ្នាក់ជាតិ, ត្រូវជា **៧,៤៨%** នៃ ផ.ស.ស. ដែលក្នុងនោះ ÷ **គម្រោងវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ** ត្រូវបានគ្រោងក្នុងទំហំប្រមាណ **៣,១៤%** នៃ ផ.ស.ស. ហើយត្រូវបានផ្ដល់អាទិភាពលើ ÷

- ការកសាង និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់, ស្ពាន, លូ ដែលរួមទាំងគម្រោងស្ថាបនាស្ពានឆ្លងកាត់ទន្លេមេគង្គ (ជីផ្ជ-ថ្មគរ), គម្រោងតំបន់អភិវឌ្ឍន៍រុនតាឯក និង ពាក់ស្នែង និង គម្រោងទឹកស្អាត ក្នុងខេត្តសៀមរាប, កម្មវិធីសាច់ប្រាក់ពលកម្ម (Cash for works) សម្រាប់សាងសង់ហេដ្ឋារចនាសម្ព័ន្ធតូចៗនៅជនបទ, ការជួសជុលឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង ក៏ដូចជាការសាងសង់ និង ជួសជុលប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធលូ អូរ ប្រឡាយរំដោះទឹកភ្លៀង និង ប្រព័ន្ធបង្ហូរទឹកកខ្វក់ ជាដើម;
- ការបន្តស្ដារ និងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ;
- ការជំរុញផលិតកម្មស្បៀង និងការលើកកម្ពស់ផលិតភាពកសិកម្ម; និង
- ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំ និង វិស័យបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ ព្រមទាំងការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាល និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និង បៃតង ក៏ដូចជា ការសាងសង់ហេដ្ឋា-រចនាសម្ព័ន្ធក្នុងវិស័យពាក់ព័ន្ធផ្សេងៗទៀត។

**ទន្ទឹមនេះ គួរកត់សម្គាល់ថា, ថវិកាឆ្នាំ ២០២៤ ក៏ត្រូវបានរៀបចំឡើង ដើម្បីគាំទ្រដល់កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦ និង ការអនុវត្តវិធានការគន្លឹះ ចំនួន ៥ សម្រាប់ដោះស្រាយអាទិភាពរបស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ដូចខាងក្រោម ÷**

**<u>កម្មវិធីគោលនយោបាយអាទិភាព ចំនួន ៦</u>** រួមមាន÷

**១-ការពង្រីកសេវាថែទាំសុខភាព** ឆ្ពោះទៅរកការគ្រប់ដណ្តប់សុខភាពជាសកល ត្រូវបានផ្តល់ថវិកាសរុបចំនួន **៣៤០,៤ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៨៣ លានដុល្លារអាម៉េរិក**;

**២-ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេស** ដល់យុវជនមកពីគ្រួសារក្រីក្រ និង គ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ត្រូវបានផ្តល់ថវិកាសរុបចំនួន **១៤៦,៦ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៣៦ លានដុល្លារអាម៉េរិក**;

**៣-ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ, ក្រុមជនងាយរងគ្រោះ**នៅក្នុងគ្រួសារក្រីក្រ និង គ្រួសារងាររងហានិភ័យ នៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និង គ្រាមានគ្រោះអាសន្ន ត្រូវបានគ្រោងថវិកាចំនួន **៦៧៤,៥ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **១៦៥ លានដុល្លារអាម៉េរិក**;

**៤-ការអនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ** ឱ្យមានលទ្ធភាពចូលរួមក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និង អាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ។ ក្នុងករណីមានតម្រូវការថវិកាចាំបាច់សម្រាប់កម្មវិធីនេះ, រាជរដ្ឋាភិបាលអាចពិនិត្យប្រើមួយផ្នែកពីកញ្ចប់ថវិកា ក្នុងទំហំប្រមាណ **៤១០ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **១០០ លានដុល្លារអាម៉េរិក** ដែលត្រូវបានត្រៀមសម្រាប់គោលនយោបាយថ្មី;

**៥-យន្តការសម្របសម្រួល និង កម្មវិធីហិរញ្ញប្បទាន** សំដៅលើកស្ទួយផលិតកម្ម, រកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ ត្រូវបានគ្រោងថវិកាចំនួន **៤១០ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **១០០ លានដុល្លារអាម៉េរិក**; និង

**៦-ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ ឃុំ-សង្កាត់** ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស ដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និង ជួយដល់គ្រួសារកសិករ ក្នុងការលើកស្ទួយផលិតផលកសិកម្មរបស់ខ្លួន និង ការរៀបចំឱ្យមានសមាគមកសិកម្មនៅតាមទីជនបទ ត្រូវបានគ្រោងថវិកាចំនួន **១៦,៩ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៤ លានដុល្លារអាម៉េរិក** ។

**<u>ការអនុវត្តវិធានការគន្លឹះ ចំនួន ៥</u>** រួមមាន៖

**១-ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ** ដោយផ្ដោតសំខាន់លើការពង្រឹងគុណភាព, ប្រសិទ្ធភាព, និង សមិទ្ធកម្មរបស់មន្ត្រី និង ស្ថាប័ន ត្រូវបានត្រៀមថវិកាចំនួន **៤៩២ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **១២០ លានដុល្លារអាមេរិក**;

**២-ការលើកកម្ពស់គុណភាពអប់រំ** ដោយផ្ដោតសំខាន់លើការពង្រឹងគុណភាពសាលារដ្ឋ ចាប់ពីថ្នាក់មត្តេយ្យ ដល់មធ្យមសិក្សា ត្រូវបានគ្រោងថវិកាចំនួន **៤១៩ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **១០២ លានដុល្លារអាមេរិក**;

**៣-ការលើកកម្ពស់គុណភាពសេវាសុខាភិបាល** ដោយផ្ដោតសំខាន់លើការពង្រឹងសមត្ថភាពផ្ដល់សេវាសុខភាពបឋមនៅមូលដ្ឋាន ត្រូវបានគ្រោងថវិកាចំនួន **២៤១ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៥៩ លានដុល្លារអាមេរិក**;

**៤-ការពង្រឹងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព"** ដោយផ្ដោតការយកចិត្តទុកដាក់ ជាពិសេសលើការកាត់បន្ថយ និង ឈានទៅដល់ការលុបបំបាត់ការជួញដូរ និង ប្រើប្រាស់គ្រឿងញៀន នៅសហគមន៍ ត្រូវបានគ្រោងថវិកាចំនួន **៣៨,១ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **៩ លានដុល្លារអាមេរិក**; និង

**៥-ការបន្តពង្រឹង និង លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌** ដោយផ្ដោតសំខាន់លើការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, ការជំរុញ និងពន្លឿនការដោះស្រាយក្ដីនៅតាមតុលាការឱ្យបានឆាប់, និងការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ត្រូវបានគ្រោងថវិកាចំនួន **១០,៣ ប៊ីលានរៀល**, សមមូលនឹងប្រមាណ **២,៥ លានដុល្លារអាមេរិក**។

## ៣.៤. ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក, និងឃុំ-សង្កាត់ខាងលើ បានធ្វើឱ្យមានឱនភាពថវិកាចំនួន **១ ៧១៨ ៩១១ លានរៀល**, ត្រូវជា **១,២០%** នៃ ផ.ស.ស., ដែលត្រូវបានគ្រោងឧបត្ថម្ភធនបំពេញតុល្យភាពដោយថវិកាថ្នាក់ជាតិ ដែលការឧបត្ថម្ភនេះកើនឡើង **១៧,៨%** ធៀបនឹងច្បាប់ឆ្នាំ ២០២៣ ក្នុងនោះ៖

